# ពុទ្ធជយមង្គល

**ពាហុំ សហស្សមភិនិម្មិតសាវុធន្តំ    គ្រីមេខលំ ឧទិតឃោរសស្សេនមារំ**
**ទានាទិ ធម្មវិធិនា ជិតវា មុនិន្ទោ    តន្តេជសា ភវតុ តេ ជយមង្គលានិ។**

*ព្រះមុនិន្ទលោកាចារ្យ    ផ្ចាញ់ក្រុងមារចិត្តមោហន្ធ*
*និម្មិតដៃមួយពាន់    កាន់សស្ត្រាវុធនានា*
*ជិះគ្រីមេខលជាតិ    កោញ្ជនាទខ្ទរពសធា*
*ព្រមដោយមារសេនា    ពន្លឹកលន់កងស័ព្ទស៊ាន*
*ដោយធម្មពិធី    ទានបារមីជាប្រធាន*
*ក្រុងមារចាញ់ទ្រង់ញាណ    ប្រណម្យកាយថ្វាយវន្ទា*
*វីជយមង្គល    ចូរមានដល់អ្នករាល់គ្នា*
*ដោយតេជៈជយា    ព្រះឈ្នះមារគ្រានោះហោង ។*

**មារាតិរេកមភិយុជ្ឈិតសព្វរត្តឹ    ឃោរម្បនាឡវកមក្ខមថទ្ធយក្ខំ**
**ខន្តីសុទន្តវិធិនា ជិតវា មុនិន្ទោ    តន្តេជសា ភវតុ តេ ជយមង្គលានិ។**

*ព្រះមុនិន្ទពិននាយកៈ    ផ្ចាញ់អាឡវៈយក្ខឃោរឃៅ*
*រឹងរូសមិនតាំងនៅ    ក្នុងខន្តីគុណសត្យា*
*របូតដល់រាត្រី    ព្រះជិនស្រីទ្រង់យុទ្ធនា*
*ក្រៃលែងក្រុងមារា    ក្នុងបឋមសម្ពោធិ*

ដោយព្រះពិធីញាណា    ទ្រង់ទូន្មានដោយខន្តី
ញ៉ាំងចិត្តអសុរី    ឲ្យបង់ព្យុះចុះវន្ទា
រីជយមង្គល    ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា    ព្រះឈ្មោះអាឡវៈយក្ខហោង ។

**នាឡាគិរឹ គជវរំ អតិមត្តភូតំ    ទាវគ្គិចក្កមសនីវ សុទារុណន្តំ**
**មេត្តម្ពុសេកវិធិនា ជិតវា មុនិន្ទោ    តន្តេជសា ភវតុ តេ ជយមង្គលានិ។**

ព្រះមុនិន្ទពិនជិនស្រី    ផ្ចាញ់ដំរីឈ្មោះនាឡា
គីរីវរៈគៈជា    ដ៏ហានក្លាចុះប្រេងព្រៀវ
សាហាវឆាវឆេះក្រៃ    ដូចភ្លើងព្រៃឆេះកំទេច
មុតដូចចក្រក្រុតពេជ្រ    ខ្លាំងដូចកាំអសនី
ដោយព្រះពិធីស្រប់    ស្រោចទឹកអប់គឺបារមី
មេត្តាព្រះជិនស្រី    ញ៉ាំងដំរីឲ្យជ្រះថ្លា
រីជយមង្គល    ចូរមានដល់អ្នករាល់គ្នា
ដោយតេជៈជយា    ព្រះឈ្មោះនាឡាគីរី ។

**ឧក្ខិត្តខគ្គមតិហត្ថសុទារុណន្តំ    ធាវន្តិយោជនបថង្គុលិមាលវន្តំ**
**ឥទ្ធីភិសង្ខតមនោ ជិតវា មនិន្ទោ    តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

ព្រះមុនិន្ទពិនលោកត្រៃ    មានព្រះទ័យធ្វើបាដិហារ្យ

*ផ្កាញ់ចោរអង្គុលិមាល៍ មានកម្រងគឺម្រាមដៃ*
*នៃមនុស្សដែលគាត់កាត់ មកដោតចាត់ជាមាល័យ*
*អង់អាចកំណាចក្រៃ ដ៏មានដៃស្ទាត់ប្រហារ*
*កាន់ដាវងាររគ្រវី ដេញព្រះមុនីសាស្តាចារ្យ*
*ចម្ងាយផ្លូវកន្តារ កណ្តាលព្រៃបីយោជនា*
*វីជយមង្គល ចូរមានដល់អ្នករាល់គ្នា*
*ដោយតេជៈជយា ព្រះឈ្នះអង្គុលិមាល៍ ។*

**កត្វាន កដ្ឋមុទ្ធរំ ឥវ គពភិនិយា ចិញ្ចាយ ទុដ្ឋវចនំ ជនកាយមជ្ឈេ**
**សន្តេន សោមវិធិនា ជិតវា មុនិន្ទោ តន្តេជសា ភវតុ តេ ជយមង្គលានិ។**

*ព្រះមុនិន្ទមានព្រះភាគ ផ្កាញ់ទ្រុស្តពាក្យនាងចិញ្ចា*
*អំពើធ្វើដូចជា ស្រីមានគភ៌ចាស់ចើងពោះ*
*យកឈើធ្វើជាកូន ព័ទ្ធពោះខ្លួនពោលទ្រគោះ*
*ព្រះពុទ្ធឈ្នះកាលនោះ ដោយសមាចារពិធី*
*រម្ងាប់ពាក្យចណ្ឌាល នាកណ្តាលជនប្រុសស្រី*
*ចិញ្ចាចាញ់បារមី គឺសច្ចៈពាក្យសត្យា*
*វីជយមង្គល ចូរមានដល់អ្នករាល់គ្នា*
*ដោយតេជៈជយា ព្រះសាស្តាឈ្នះចិញ្ចា ។*

**សច្ចំ វិហាយ មតិសច្ចកវាទកេតុំ   វាទាភិរោបិតមនំ អតិអន្ធភូតំ**

**បញ្ញាបទីបជលិតោ ជិតវា មុនិន្ទោ   តន្តេជសា ភវតុ តេ ជយមង្គលានិ។**

*ព្រះមុនិន្ទពិនអ្នកប្រាជ្ញ   រុងរឿងស្វាចដោយបញ្ញា*

*ផ្ចាញ់សច្ចកៈជា   និគ្រន្ថក្រៅពុទ្ធវិន័យ*

*អធ្យាស្រ័យលះបង់   ពាក្យសត្យត្រង់តាមគាប់ចៃ*

*សរសើរខ្លួនឯងក្រៃ   លើកកំពស់ដូចដងទង់*

*បង្កើតម្ចូរងងឹត   ដោយពោលឥតពាក្យទៀងត្រង់*

*ព្រះទ្រង់កំចាត់បង់   ដោយប្រទីបគឺបញ្ញា*

*វិជយមង្គល   ចូរមានដល់អ្នករាល់គ្នា*

*ដោយតេជៈជយា   ឈ្នះសច្ចៈកៈនិគ្រន្ថ ។*

**នន្ទោបនន្ទភុជគំ វិពុធំ មហិទ្ធឹ   បុត្តេន ថេរភុជគេន ទមាបយន្តោ**

**ឥទ្ធូបទេសវិធិនា ជិតវា មុនិន្ទោ   តន្តេជសា ភវតុ តេ ជយមង្គលានិ ។**

*ព្រះមុនិន្ទពិនទ្រង់ញាណ   ញ៉ាំងមោគ្គល្លានមានអំណាច*

*ឲ្យប្លែងជានាគរាជ   ទៅទូន្មានព្យុះភុជង្គ*

*ឈ្មោះនន្ទោបៈនន្ទ   ចិត្តមោហន្ទរឿងឫទ្ធិរុង*

*ទិដ្ឋិកាចទ្រនង់   ទ្រង់ផ្ចាញ់ដោយពិធីឈាន*

*គឺឲ្យឧបាទេស   ឫទ្ធិវិសេសដល់មោគ្គល្លាន*

*ឫទ្ធិនាគអន្តរធាន* *ឱនចុះចាញ់ព្រះសាស្ដា*
*វីជយមង្គល* *ចូរមានដល់អ្នករាល់គ្នា*
*ដោយតេជៈជយា* *ព្រះភគវាឈ្នះនាគហោង។*

**ទុគ្គាហទិដ្ឋិភុជគេន សុទដ្ឋហត្ថំ ព្រហ្មំ វិសុទ្ធិជុតិមិទ្ធិពកាភិធានំ**
**ញាណាគទេន វិធិនា ជិតវា មុនិន្ទោ តន្តេជសា ភវតុ តេ ជយមង្គលានិ។**

*ព្រះមុនិន្ទពិនគោតម* *ផ្ចាញ់មហាព្រហ្មឈ្មោះពកា*
*សំគាល់ថាអាត្មា* *រុងរឿងដោយគុណបរិសុទ្ធ*
*ដៃកាន់អាសិរ្ពិស* *គឺចិត្តទ្រឹស្ដដ៏មុះមុត*
*កាន់ខុសផ្លូវសម្ពុទ្ធ* *មិនលើកលាកលះបង់ប្រាណ*
*ទ្រង់ឈ្នះដោយពិធី* *ឱសថវិសេសសម្រាន្ត*
*ផ្សំត្រូវគាប់សន្តាន* *គឺព្រះញាណប្រោសទេសនា*
*វីជយមង្គល* *ចូរមានដល់អ្នករាល់គ្នា*
*ដោយតេជៈជយា* *ឈ្នះព្រហ្មាឥតមានហ្មង ។*

**ឯតាបិ ពុទ្ធជយមង្គលអដ្ឋគាថា យោ វាចនោ ទិនទិនេ សរតេ មតន្ទី**
**ហិត្វានេកវិវិធា ចុបទ្ទវានិ មោក្ខំ សុខំ អធិគមេយ្យ នរោ សបញ្ញោ។**

**យោនរោ** *ជនឯណា* *កបបញ្ញាប្រាសក្ដីខ្ជិល*
*ឧស្សាហ៍សាងទានសីល* *សូត្ររំលឹកព្រះធម៌ថ្លៃ*

គាថាប្រាំបីបទ　　នេះកំណត់ឈ្មោះពុទ្ធជ័យ
ខំសូត្រសព្វ ៗ ថ្ងៃ　　កើតមង្គលជានិរន្តរ៍
**សោនរោ** វីជននោះ　　បានរំដោះរោគអាសន្ន
ឧបទ្រពអនេកលន់　　មានប្រការផ្សេង ៗ ផង
នឹងដល់សុខក្សេមក្សាន្ត　　គឺនិព្វានសុខកន្លង
លែងទុក្ខទាំងបួនកង　　ដោយពុទ្ធជ័យមង្គលនេះ ។

